# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៥

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ២០៩,១៣៥ ដុល្លារអាមេរិក សម្រាប់ការអនុវត្តគម្រោងផ្នែកអប់រំចំនួនបី

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់**ថវិកាសរុបចំនួន ២០៩,១៣៥ ដុល្លារអាមេរិក** ដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងអង្គការ Samaritan's Purse International Relief ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបីសម្រាប់គម្រោងដូចតទៅ៖

**១. គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅអនុវិទ្យាល័យកែវព័ណ៌ ក្នុងស្រុកពួក ខេត្តសៀមរាប (ថវិកាចំនួន ៥២,៤០០ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប

គម្រោងនេះ គឺដើម្បីសាងសង់អគារសិក្សាមួយខ្នងដែលបំពាក់ទៅដោយបរិក្ខារសិក្សា និងបន្ទប់ទឹក នៅអនុវិទ្យាល័យកែវព័ណ៌ ខេត្តសៀមរាប។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សប្រមាណជា ២៣៣នាក់ នឹងអាចសិក្សានៅក្នុងថ្នាក់រៀនថ្មី ដោយមានចំនួនសិស្សតិចជាងមុនក្នុងមួយថ្នាក់ៗ ជាមួយនឹងបរិស្ថាននៃការអប់រំប្រកបដោយផាសុខភាពជាងមុន ។

**២. គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅអនុវិទ្យាល័យឃីឡាំក ក្នុងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ (ថវិកាចំនួន ៦៧,៦៣១ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ

គម្រោងនេះ គឺដើម្បីសាងសង់អគារសិក្សាមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សា ជាមួយនឹងបន្ទប់ទឹក នៅអនុវិទ្យាល័យឃីឡាំក ខេត្តបន្ទាយមានជ័យ។ គម្រោងនេះត្រូវបានរំពឹងថា សិស្សានុសិស្សប្រមាណជា ២៨២នាក់ នឹងអាចសិក្សានៅក្នុងថ្នាក់រៀនថ្មីប្រកបដោយសុវត្ថិភាព និងផាសុខភាពជាងមុន ។

**៣. គម្រោងសាងសង់អគារសិក្សាពីរខ្នង នៅសាលាបឋមសិក្សាខ្លែងពណ៌ និងសាលាបឋមសិក្សាតាដុល ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ (ថវិកាចំនួន ៨៩,១០៤ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ អង្គការSamaritan's Purse International Relief

គម្រោងនេះ គឺដើម្បីសាងសង់អគារសិក្សាពីរខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សា នៅសាលាបឋមសិក្សាខ្លែងពណ៌ និងសាលាបឋមសិក្សាតាដុល ក្នុងខេត្តបន្ទាយមានជ័យ។ គម្រោងនេះត្រូវបានរំពឹងថា សិស្សានុសិស្សប្រមាណជា ២៨១នាក់ នឹងអាចធ្វើការសិក្សានៅក្នុងថ្នាក់រៀនថ្មីប្រកបទៅដោយសុវត្ថិភាព និងផាសុខភាពជាងមុន។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់**ថវិកាជាង៥៤លានដុល្លារអាមេរិក**ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិ**ចំនួន៥៤៤ គម្រោង**នៅទូទាំងប្រទេស។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*